# និយោជកទាំងឡាយណាដែលកេងប្រវ័ញ្ចបុគ្គលិកអន្តោប្រវេសន៍រងនូវការហាមឃាត់ពីការជួលអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នមួយរយៈ

តាមរយៈច្បាប់ពង្រឹងការគោរពតាមច្បាប់របស់និយោជក ច្បាប់ថ្មីៗដែលការពារកម្មករអន្តោប្រវេសន៍ពីការកេងប្រវ័ញ្ចចាប់ផ្តើមចូលជាធរមាននៅថ្ងៃទី 1 កក្កដា 2024។

សេចក្តីប្រកាសពីការហាមឃាត់មានគោលបំណងដើម្បីការពារបុគ្គលិកអន្តោប្រវេសន៍ងាយរងគ្រោះពីការកេងប្រវ័ញ្ច និងលើកកម្ពស់ការគោរពច្បាប់របស់និយោជក និងអ្នកផ្តល់សេវាកម្មភាគីទីបីទាំងឡាយ។

គេអាចចេញសេចក្តីប្រកាសទាំងនេះប្រសិនបើបុគ្គលណា ឬអាជីវកម្មណាមួយល្មើសផ្នែកណាមួយនៃច្បាប់អន្តោប្រវេសន៍ ច្បាប់យុត្តិធម៌ការងារ ឬផ្នែកផ្សេងៗនៃច្បាប់ព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើកម្មករអន្តោប្រវេសន៍បណ្តោះអាសន្ន។ សេចក្តីប្រកាសនេះក៏អាចធ្វើបានផងដែរប្រសិនបើបុគ្គល ឬអាជីវកម្មទាំងឡាយមិនគោរពតាមសេចក្តីជូនដំណឹងពីការគោរពតាមច្បាប់កិច្ចសន្យាដែលអាចអនុវត្តបាន ឬកាតព្វកិច្ចធានាផ្សេងៗ។

និយោជក ឬភាគីទីបីផ្តល់សេវាកម្មទាំងឡាយណាដែលរងនូវការហាមឃាត់នឹងត្រូវផ្សព្វផ្សាយពីឈ្មោះ និងលេខអាជីវកម្ម (ABN) នៅតាម គេហទំព័រកងកម្លាំងការពារព្រំដែនអូស្ត្រាលី។ បន្ទាប់ពីការហាមឃាត់ចប់ ពួកគេអាចជួលបុគ្គលិកអន្តោប្រវេសន៍ម្តងទៀត ប៉ុន្តែត្រូវតែគោរពតាមតម្រូវការរាយការណ៍ផ្សេងៗ។

វាជាបទល្មើសព្រហ្មទណ្ឌក្នុងការរំលោភសេចក្តីប្រកាសហាមឃាត់។ ការផាកពិន័យរួមមាន ៖

- ជាប់ពន្ធនាគាររហូតដល់ 2ឆ្នាំ, ពិន័យចំនួន 360 ឯកតាពិន័យ (បច្ចុប្បន្ននេះផាកពិន័យ $118,800) ឬទាំងពីរ ឬការផាកពិន័យស៊ីវិលចំនួន 240 ឯកតាពិន័យ (បច្ចុប្បន្ននេះផាកពិន័យ $79,200) សម្រាប់បុគ្គល។
- ការផាកពិន័យរហូតដល់ 1,800ឯកតាពិន័យ (បច្ចុប្បន្ននេះផាកពិន័យ $594,000) ចំពោះករណីឧក្រិដ្ឋ ឬការពិន័យស៊ីវិលរហូតដល់ 1,200 ឯកតាពិន័យ (បច្ចុប្បន្ននេះផាកពិន័យ $396,000) សម្រាប់សាជីវកម្ម។

បុគ្គលិកអន្តោប្រវេសន៍ត្រូវបានលើកទឹកចិត្តឲ្យរាយការណ៍ពីករណីកេងប្រវ័ញ្ចទៅកាន់ គណៈកម្មាធិការយុត្តិធម៌ការងារ ឬអ្នកឃ្លាំមើលព្រំដែន។

## តើនិយោជកដែលត្រូវបានហាមឃាត់ត្រូវបានរារាំងមិនឲ្យធ្វើអ្វីខ្លះ ?

និយោជកដែលរងនូវការហាមឃាត់ ( ទាំងឯកតបុគ្គល ឬសាជីវកម្ម) មិនអាចជួលបុគ្គលិកកាន់ទិដ្ឋាការបណ្ដោះអាសន្នបានទេ ក្នុងអំឡុងពេលមួយ។

## តើសេចក្ដីប្រកាសពីការហាមឃាត់និយោជកមានរយៈពេលប៉ុន្មាន ?

- គ្មានរយៈពេលអតិបរមាសម្រាប់បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងទាសភាពបែបសម័យទំនើបនោះទេ។
- ជាប់ទោសអតិបរមា 10ឆ្នាំសម្រាប់បទល្មើសព្រហ្មទណ្ឌ (ក្រៅពីបទល្មើសទាំងឡាយណាពាក់ព័ន្ធនឹងការជួញដូរមនុស្ស និង ទាសភាពបែបសម័យទំនើប )។
- រហូតដល់ 5ឆ្នាំសម្រាប់ការដាក់ទណ្ឌកម្មបុគ្គលិកអន្តោប្រវេសន៍ផ្សេងទៀត។

## តើមានអ្វីកើតឡើងចំពោះបុគ្គលិករបស់និយោជកដែលរងការហាមឃាត់ ?

គ្មានការផាកពិន័យលើបុគ្គលិកអន្តោប្រវេសន៍នោះទេ។ បុគ្គលិកស្រាប់របស់និយោជកដែលរងការហាមឃាត់អាចជ្រើសរើសបន្ត ឬមិន បន្តបំពេញការងារជាមួយនិយោជកនោះក៏បាន។

## តើនិយោជកអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងបម្រាមទេ ?

បាន។ និយោជក/ភាគីទីបីនឹងទទួលបានសេចក្ដីជូនដំណឹងមួយគូសបញ្ជាក់ពីមូលហេតុផ្សេងៗពីលទ្ធភាពនៃការចេញបម្រាម។ ពួកគេ មានពេល 28ថ្ងៃ ឬរយៈពេលគូសបញ្ជាក់នៅក្នុងលិខិត ដើម្បីធ្វើការដាក់ជូនសេចក្ដីពន្យល់ផ្សេងៗថាហេតុអ្វីបានជាពួកគេមិនគួរត្រូវ បានប្រកាសថាជានិយោជករងការហាមប្រាម។

| | | | |
|---|---|---|---|
| សិទ្ធិបុគ្គលិកអន្តោប្រវេសន៍ | ច្បាប់កេងប្រវ័ញ្ចបុគ្គលិក អន្តោប្រវេសន៍ថ្មី | គណៈកម្មាធិការយុត្តិធម៌កន្លែង ការងារ ( Fair Work Ombudsman ) | អ្នកឃ្លាំមើលព្រំដែន |